ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
រដ្ឋបាលព្រៃឈើ
FORESTRY ADMINISTRATION

លេខ: ២៧៣០០ ន.ព. ៩៧៨

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល លេខ ៤០៨០ ថ្ងៃទី ២០.១២.១៣ បញ្ជូន

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**
**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ករណីសារព័ត៌មានភ្នំពេញប៉ុស្តិ៍ចុះផ្សាយអត្ថបទ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ក្រោមចំណងជើងថា "**រូបភាពពីផ្កាយរណបបង្ហាញថាព្រៃឈើកម្ពុជាសល់ ៤៦ភាគរយ**"។

ជូនភ្ជាប់ -ចំណិតអត្ថបទសារព័ត៌មានភ្នំពេញប៉ុស្តិ៍ចុះផ្សាយថ្ងៃសុក្រ ទី១៣ ខែធ្នូ ឆ្នាំ២០១៣
-រូបភាពផ្ទៀងផ្ទាត់ផែនទីគម្របព្រៃឈើ ដែលធ្វើការបកស្រាយដោយ Open Development Cambodia (ODC)
-តារាងទិន្នន័យរូបភាពផ្កាយរណប Landsat 8 ថតនៅឆ្នាំ២០១៣ ដែល ODC ប្រើប្រាស់ក្នុងការបកស្រាយគម្របព្រៃឆ្នាំ ២០១៣
- សៀវភៅធនធានគម្របព្រៃឈើកម្ពុជា ឆ្នាំ ២០១០

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា៖ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានធ្វើការចុះផ្សាយអត្ថបទជារបាយការណ៍របស់ Open Development Cambodia (ODC) លើករណីបម្រែបម្រួលគម្របព្រៃឈើ ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ ២០១៣។ យោងតាមអត្ថបទនោះ រដ្ឋបាលព្រៃឈើបានតាមដានធ្វើការពិនិត្យលម្អិតទៅលើខ្លឹមសារដែលមាននៅក្នុងគេហទំព័រផ្ទាល់របស់ ODC ពាក់ព័ន្ធនឹងការវាយតម្លៃគម្របព្រៃឈើ និងផែនទីគម្របព្រៃឈើ ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ២០១៣ ដោយអាចសន្និដ្ឋានជារួមបានថា ទិន្នន័យផែនទីផលិតដោយ ODC នេះ មានភាពមិនច្បាស់លាស់ច្រើន បើផ្អែកតាមគោលការណ៍បច្ចេកទេសសំខាន់ៗដែលចាំបាច់ក្នុងការវាយតម្លៃគម្របព្រៃឈើ។ ភាពមិនច្បាស់លាស់ទាំងនោះមានជាអាទិ៍ ៖

**១-និយមន័យព្រៃឈើ**

និយមន័យព្រៃឈើជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់ធ្វើការវាយតម្លៃគម្របព្រៃ។ នៅលើពិភពលោកបច្ចុប្បន្ននេះ ការប្រើប្រាស់និយមន័យព្រៃឈើ មានប្រមាណជាង ២៥០ និយមន័យផ្សេងៗគ្នា ពោលគឺមិនទាន់មានការឯកភាពគ្នាក្នុងការប្រើប្រាស់និយមន័យព្រៃឈើនេះនៅឡើយទេ។ ការប្រើប្រាស់និយមន័យអាស្រ័យតាមគោលបំណងនៃការប្រើប្រាស់របស់ប្រទេស និន្នាការនយោបាយ បក្សពួក ក្រុម ឬគម្រោងនីមួយៗ។ មុនឆ្នាំ១៩៧០ កម្ពុជាយើង បានប្រើប្រាស់និយមន័យព្រៃឈើតាមអង្គការស្បៀង និងកសិកម្ម ( FAO ) ដែលកំណត់ថា គេអាចចាត់ទុកជាព្រៃឈើបានលុះត្រាតែដីនោះមានដុះរុក្ខជាតិគ្របដណ្តប់ដីចាប់ពី ១០ភាគរយ និងមានទំហំផ្ទៃដីចាប់ពីកន្លះហិកតាឡើងទៅ។

អាស័យដ្ឋានលេខ ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: (០២៣) ២១៤ ៦៥១ ទូរសារ: (៨៥៥) ២៣ ២១២ ២០១
N° 40, Preah Norodom Blvd, Sangkat Phsar Kandal 2, Khan Daun Penh, Cambodia Phone: (023) 214 651 Fax : (855) 23 212 201

តាមនិយមន័យនេះ កម្ពុជាយើងមានផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើប្រមាណ ៧៣ ភាគរយ។ នៅឆ្នាំ ១៩៩៣ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការ GTZ (អាល្លឺម៉ង់) ប្រទេសកម្ពុជា វៀតណាម ឡាវ និងថៃ បានកសាងផែនទីគម្របព្រៃឈើដោយកំណត់យកនិយមន័យព្រៃឈើខុសពី FAO ត្រង់ចំណុចការចាត់ទុកជាព្រៃទាល់តែមានរុក្ខជាតិដុះគ្របដណ្តប់ដីចាប់ពី ២០ភាគរយ ឡើងទៅ ជាហេតុធ្វើឲ្យផ្ទៃដីព្រៃឈើដែលមានគម្របរុក្ខជាតិគ្របដណ្តប់ពី ១០ ទៅ ១៩ភាគរយ លែងជាតំបន់ព្រៃឈើទៅវិញ។ ដូចគ្នាដែរ មានការសិក្សាខ្លះបានសន្និដ្ឋានថា គម្របព្រៃឈើនៅកម្ពុជានៅសល់ប្រមាណ៣០ភាគរយ ធ្វើឲ្យអ្នកទទួលព័ត៌មានមានការយល់ច្រឡំ តែតាមការពិតការសិក្សានោះគេសិក្សាពីព្រៃដែលមានកម្រិតគ្របដណ្តប់ដោយរុក្ខជាតិចាប់ពី ៦០ភាគរយ ឡើងទៅ ដែលជាការវាយតម្លៃគម្របព្រៃស្រោង និងពាក់កណ្តាលស្រោងតែប៉ុណ្ណោះ មិនមែនព្រៃឈើគ្រប់ប្រភេទនៅកម្ពុជានោះឡើយ។ រីឯកំហុសធ្ងន់មួយទៀតដែលតែងកើតមានឡើងនោះគឺ វាយតម្លៃខុសទៅលើចំណាត់ព្រៃឈើ និងចំណាត់ថ្នាក់ដីមិនមែនព្រៃឈើ។

**២-ទិន្នន័យមានកម្រិតលំអៀងធំដែលតាមទ្រឹស្តីបច្ចេកទេសមិនអាចទទួលយកបាន**(**ពិសេសលទ្ធផលឆ្នាំ២០១៣**)

ក-ចំនុចខ្វះចន្លោះលើកិច្ចដំណើការវាយតម្លៃចំណាត់ថ្នាក់ព្រៃ

- ជាការចាំបាច់ណាស់ អ្នកបច្ចេកទេសក្នុងការបកស្រាយរូបភាពពីផ្កាយរណបត្រូវមានបទពិសោធន៍ការងារមួយគ្រប់គ្រាន់ ដែលកិច្ចការនេះទាមទារឲ្យមានអ្នកបច្ចេកទេសបកស្រាយរូបភាពមានបទពិសោធន៍គ្រប់គ្រាន់តាំងពីបច្ចេកទេសជំនាញព្រៃឈើ GIS Remote Sensing និងការចុះផ្ទៀងផ្ទាត់នៅទីវាល (Ground Truth) ព្រមទាំងរូបភាពផ្កាយរណបមានគុណភាពខ្ពស់ទើបធ្វើឲ្យលទ្ធផលនោះអាចមានភាពជាក់លាក់។ ជាក់ស្តែងនៅក្នុងអត្ថបទរបស់ ODC ត្រង់ចំនុច " **នរណាជាអ្នកផលិតផែនទីទាំងអស់នេះ?** "ពុំបានបង្ហាញពីជំនាញបច្ចេកទេសច្បាស់លាស់របស់អ្នកផលិតផែនទីនោះទេ ក្រៅពីការបញ្ជាក់ថាអ្នកបកស្រាយបានទទួលការបណ្តុះបណ្តាលដោយអ្នកជំនាញមកពីសាកលវិទ្យាល័យកាន់ធឺវៀតណាម (Vietnam's Can Tho University)ហើយម្យ៉ាងទៀត តំបន់ដែលបាំងដោយពពកត្រូវបានគេចាត់ទុកថាជាតំបន់មិនមែនព្រៃ ដែលនេះជាការបាត់បង់ព័ត៌មានពីព្រៃឈើដែលពពកបាំងនាំឲ្យបាត់បង់ផ្ទៃដីព្រៃដោយសារការប្រើប្រាស់រូបភាពផ្កាយរណបមិនមានគុណភាពអាចទទួលយកបាន រីឯការរៀបចំនេះអាចមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការផ្ទៀងផ្ទាត់នៅទីវាល ក៏ដូចជាគុណភាពរបស់អ្នកបកស្រាយមិនអាចជឿជាក់បានឡើយ។ (អត្ថបទបញ្ជាក់ថាគម្រោងទើបចាប់អនុវត្តក្នុងខែមិថុនា ២០១៣)
- អ្នកបកស្រាយមិនបានបំពេញលក្ខខណ្ឌពីរសំខាន់នោះគឺ ការចុះទីវាលផ្ទៀងផ្ទាត់លទ្ធផលផែនទីបឋម និងការវាយតម្លៃកម្រិតជឿជាក់លើគុណភាពផែនទីពីសំណាក់ភាគីទី៣ (ជាភាគីឯករាជ្យ) មុននឹងអាចសម្រេចជាលទ្ធផលផែនទីចុងក្រោយបាន
- ការយករូបភាពផ្កាយរណបមកវាយតម្លៃគម្របព្រៃស្ថិតក្នុងរដូវខុសគ្នា ក៏ជាកំហុសធ្ងន់ធំក្នុងការចាត់ថ្នាក់ប្រភេទព្រៃផងដែរ (រដូវប្រាំង-វស្សា)
- ចំពោះការចាត់ថ្នាក់គម្របព្រៃឈើឆ្នាំ២០០៩ ODC បានប្រើប្រាស់ទិន្នន័យរូបភាពផ្កាយរណបដែលខូចមានបន្ទាត់កាត់ទទឹងដែលបង្កើតឲ្យមានចន្លោះប្រហោងទិន្នន័យ (Landsat 7 TM+ SLC-off ដូចមានបង្ហាញនៅក្នុងឯកសារជូនភ្ជាប់រូបភាព)

- បើធ្វើការពិនិត្យមើលទៅលើផែនទីគម្របព្រៃឈើនៅក្នុងគេហទំព័ររបស់ ODC ឃើញថា លទ្ធផលនៃការបកស្រាយមានកំហុស ត្រង់ព្រំប្រទល់តភ្ជាប់ពីរូបភាពផ្កាយរណបមួយទៅរូបភាពផ្កាយរណបមួយទៀតដោយធ្វើការចាត់ថ្នាក់ប្រភេទព្រៃតាមគែមរបស់រូបភាពផ្កាយរណប មិនមានភាពស៊ីមេទ្រីគ្នាទៅតាមចំណាត់គម្របព្រៃធម្មជាតិជាក់ស្តែង។ កំហុសនេះកើតឡើង ដោយសារតែខ្វះបច្ចេកទេសក្នុងការធ្វើប្រព្រឹត្តកម្មទិន្នន័យរូបភាពផ្កាយរណបមុននឹងចាប់ផ្តើមធ្វើការបកស្រាយនិងមិនមានការផ្ទៀងផ្ទាត់ស្ថានភាពលើទីតាំងជាក់ស្តែង (ដូចមានបង្ហាញនៅក្នុងឯកសារជូនភ្ជាប់រូបភាព)
- ចំពោះការចាត់ថ្នាក់បំរែបំរួលគម្របព្រៃឈើ របស់ ODC ពីឆ្នាំ២០០៩ មកឆ្នាំ ២០១៣ គឺមានលំអៀងធំដោយសារបច្ចេកទេស ព្រោះការប្រើប្រាស់រូបភាពផ្កាយរណប Landsat 7TM+ SLC-off ដែលខូចមានចន្លោះប្រហោងទិន្នន័យច្រើន ហើយរូបភាពផ្កាយរណប Landsat 8 ចាប់យកនៅឆ្នាំ២០១៣ មានអត្រាពពកបាំងច្រើនលើសពី២០ភាគរយនៃផ្ទៃសរុប ដែលជាបច្ចេកទេសរូបភាពបែបនេះគេមិនអាចទទួលយកមកបកស្រាយបានឡើយ។

ខ-ចំពោះលទ្ធផល ៤៦,៣៣ % ក្នុងឆ្នាំ ២០១៣

- គ្រប់ផ្ទាំងរូបភាពផ្កាយរណប Landsat 8 មានកម្រិតបាំងនៃពពកលើសពី២០ % ក្នុងផ្ទាំងខ្លះ ហើយផ្ទាំងខ្លះទៀតមានពពកបាំងរហូតដល់ទៅជាង ៦០% តាមទ្រឹស្តីបច្ចេកទេសគឺមិនអាចយកមកវាយតម្លៃបានទេ ទោះជាត្រឹមកម្រិតសិក្សាស្រាវជ្រាវក៏ដោយ។ មានន័យថា លទ្ធផល៤៦,៣៣% ដែល ODC បានបង្ហាញនោះ មិនអាចទទួលយកមកប្រើប្រាស់បានឡើយ ព្រោះកម្រិតពពកធំៗបាំងច្រើន នាំឲ្យបាំងផ្ទៃនានានៃតំបន់ព្រៃឈើនៅខាងក្រោមពពក ហើយការបកស្រាយរូបភាពពពកនិងស្រមោលពពក នៅលើរូបភាពផ្កាយរណបនោះមានភាពច្រឡំក្នុងការចាត់ថ្នាក់ចូលទៅក្នុងដីមិនមានគម្របព្រៃ(រូបភាពជូនភ្ជាប់)។
- ក្នុងទិន្នន័យរបស់ ODC មិនមានការកំណត់មាត្រដ្ឋានអប្បបរមារបស់ផែនទី(Minimum mapping Unit) ដែលជាលក្ខណៈសំខាន់ក្នុងការចាត់ថ្នាក់គម្របព្រៃឈើ
- ការវាយតម្លៃគម្របព្រៃឈើរបស់ ODCពេលនេះគ្របដណ្តប់ទូទាំងប្រទេស មិនបានបញ្ជាក់ថាការបកស្រាយផែនទីគម្របព្រៃឈើរបស់ខ្លួន អនុវត្តតាមប្រភពនិយមន័យណាមួយច្បាស់លាស់នៅឡើយទេហើយពិសេសទៅទៀតនោះ មិនមានការបញ្ជាក់ទទួលស្គាល់ពីកម្រិតជឿជាក់នៃការបកស្រាយដោយភាគីឯករាជ្យដែលមានជំនាញច្បាស់លាស់និងមានការទទួលស្គាល់ប្រើប្រាស់ជាទូទៅនោះឡើយ។

**៣-សេចក្តីសន្និដ្ឋាន**

ករណីនេះ រដ្ឋបាលព្រៃឈើបាននិងកំពុងព្យាយាមស្វែងរកផ្ទាំងរូបភាពផ្កាយរណបមានគុណភាពល្អ (កម្រិតបាំងពពកមិនលើសពី៨%) ដើម្បីធ្វើការបកស្រាយគម្របព្រៃឈើក្នុងឆ្នាំ២០១៣ ដែរតែដោយសារពុំអាចរករូបភាពមានគុណភាពអាចទទួលយកបាននោះ កិច្ចការនេះត្រូវរង់ចាំរូបភាពផ្កាយរណបឆ្នាំ២០១៤ ឬ២០១៥ ដើម្បីយកមកបកស្រាយវាយតម្លៃបម្រែបម្រួលគម្របព្រៃឈើជាបន្តទៀត។ ជាទូទៅ ការវាយតម្លៃបម្រែបម្រួលគម្របព្រៃឈើ បានធ្វើក្នុងរយៈពេលពី ៣ ទៅ ៥ឆ្នាំ ម្តង អាស្រ័យទៅតាមលទ្ធភាពថវិកាដែលអាចរកបាន។ ចាប់ពីឆ្នាំ១៩៩៣ មកដល់ពេលនេះ រដ្ឋបាលព្រៃឈើបានធ្វើការវាយតម្លៃគម្របព្រៃឈើកម្ពុជាបានចំនួន ៥ដងហើយ គឺលើកទីមួយនៅឆ្នាំ១៩៩២-៩៣ លើកទីពីរឆ្នាំ១៩៩៦-៩៧ លើកទីបី ឆ្នាំ២០០២ ឆ្នាំលើកទីបួន ឆ្នាំ២០០៥-២០០៦ និង

លើកទីប្រាំនៅឆ្នាំ២០១០ (ទិន្នន័យប្រៀបធៀបមានក្នុងសៀវភៅ **ធនធានគម្របព្រៃឈើកម្ពុជាឆ្នាំ ២០១០** ចេញផ្សាយខែតុលា ឆ្នាំ២០១១ ឧបត្ថម្ភដោយគម្រោង ITTO និងឧបត្ថម្ភបោះពុម្ពផ្សាយដោយDANIDA)។ ការបកស្រាយរូបភាពផ្កាយរណបដើម្បីផលិតផែនទីគម្របព្រៃឈើកម្ពុជាត្រូវបានរៀបចំឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើដែលមានជំនាញច្បាស់លាស់ទទួលបានការបណ្តុះបណ្តាលរយៈពេលវែង-ខ្លី ពីសាកលវិទ្យាល័យ និងស្ថាប័នបច្ចេកទេសនានាពីប្រទេសជប៉ុន កូរ៉េ អូស្ត្រាលី ដាណឺម៉ាក្ស ថៃ ហើយមន្ត្រីទាំងនោះមានបទពិសោធន៍យូរឆ្នាំ ព្រមទាំងទទួលបានការបំប៉នបច្ចេកទេសជំនាញបន្ថែមជារៀងរាល់ឆ្នាំទៀតផង។ រីឯរូបភាពផ្កាយរណបដែលរដ្ឋបាលព្រៃឈើបានប្រើកន្លងមក គឺអនុលោមតាមបច្ចេកទេសដ៏ត្រឹមត្រូវ គឺប្រើប្រាស់រូបភាពផ្កាយរណបមានគុណភាពខ្ពស់ ហើយផែនទីគម្របព្រៃដែលទទួលបានសុទ្ធតែមានការបញ្ជាក់ទទួលខុសត្រូវពីភាពអាចជឿជាក់បានពីភាគីទីបីដែលឯករាជ្យមានជំនាញ និងបទពិសោធន៍ខ្ពស់ទទួលស្គាល់ដោយអន្តរជាតិ។

សរុបសេចក្តីមកផែនទីដែល ODC ផលិតផ្សាយក្នុងគេហទំព័រខ្លួនហើយផ្តល់ការសន្និដ្ឋានថា គម្របព្រៃឈើកម្ពុជាឆ្នាំ២០១៣ នៅសល់ត្រឹម ៤៦ ,៣៣ភាគរយ ជាតួលេខមួយដែលមិនមានការបញ្ជាក់ពីភាគីជំនាញទី៣ ដែលឯករាជ្យ ហើយតួលេខនេះមិនមានមូលដ្ឋានបច្ចេកទេសសមស្រប ដែលអាចជឿជាក់ និងយកមកប្រើប្រាស់បាននោះឡើយ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយអនុគ្រោះតាមការគួរ។

**បណ្ឌិត ឆេង គីមស៊ុន**

# លទ្ធផលផ្ទៀងផ្ទាត់ផែនទីគម្របព្រៃឈើរបស់ ODC

ផែនទីគម្របព្រៃឈើ 2013 របស់ ODC    រូបភាពផ្កាយរណប Landsat 8 2013




ប្រភេទគម្របព្រៃតែមួយ ប៉ុន្តែ ODC បកស្រាយចេញជាពីរចំណាត់ថ្នាក់

ផែនទីគម្របព្រៃឈើ 2013 របស់ ODC    រូបភាពផ្កាយរណប Landsat 8 2013




ប្រភេទគម្របព្រៃតែមួយ ប៉ុន្តែ ODC បកស្រាយចេញជាពីរចំណាត់ថ្នាក់

ផែនទីគម្របព្រៃឈើ 2013 របស់ ODC　　　រូបភាពផ្កាយរណប Landsat 8 2013




កំហុសនៃការចាត់ថ្នាក់ របស់ ODC ទីតាំងស្រមោលពពកត្រូវបានចាត់ថ្នាក់ជាដីមិនមានគម្របព្រៃ

រូបភាពផ្កាយរណប ឆ្នាំ២០០៩ Landsat 7TM+ SLC-off ដែល ODC ប្រើប្រាស់ក្នុងការចាត់គម្របព្រៃឈើឆ្នាំ ២០០៩



រូបភាពផ្កាយរណប 12651-ថតនៅឆ្នាំ2009



រូបភាពផ្កាយរណប 12850-ថតនៅឆ្នាំ2009


Forest Cover 2013 (ODC)
Legend
Country Boundary
Dense Forest
Mixed Forest
Water
Non Forest
Cloud


Forest Cover 2009 (ODC)
Legend
Country Boundary
Dense Forest
Mixed Forest
Water
Non Forest
Cloud


Forest Cover 2004 (ODC)
Legend
Country Boundary
Dense Forest
Mixed Forest
Water
Non Forest
Cloud


Forest Cover 2000 (ODC)
Legend
Country Boundary
Dense Forest
Mixed Forest
Water
Non Forest
Cloud


Forest Cover 1989 (ODC)
Legend
Country Boundary
Dense Forest
Mixed Forest
Water
Non Forest
Cloud


Forest Cover 1973 (ODC)
Legend
Country Boundary
Dense Forest
Mixed Forest
Water
Non Forest
Cloud